# English for Study in Australia
# កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

## LESSON 11 – I got the job!
## មេរៀនទី១០ ៖ ខ្ញុំបានការងារធ្វើហើយ!

**STUDY NOTES**
**ឯកសារជំនួយមេរៀន**

តួអង្គ
Angel:
អែនជល ៖ ជានិស្សិតបរទេស ហើយមកប្រទេសអូស្ត្រាលីជាលើកទី១។
Bill :
បៀល ៖ ជាអ្នកគ្រប់គ្រងនៅក្នុងហាងលក់ខោខូវប៊ិយ។

សាច់រឿង
អែនជល ចូលទៅក្នុងហាងលក់ខោខូវប៊ិយ ហើយឆ្លងកាត់ការសម្ភាសក្រៅផ្លូវការមួយជាមួយអ្នកគ្រប់គ្រងឈ្មោះ បៀល។

**ព័ត៌មាន-លក្ខខណ្ឌការងារ**
នេះគឺជាបញ្ជីលក្ខខណ្ឌការងារទូទៅនៅប្រទេសអូស្ត្រាលី ដែលមាននិយមន័យ និងការពន្យល់បកស្រាយ។

| | |
|---|---|
| Award (wages) | បៀវត្សរ៍ក្នុងកម្រិតអប្បបរមា ដែលនិយោជកប្រគល់ជូនលោកអ្នក ជាថ្នូរនឹងការងារដែលលោកអ្នកបានធ្វើ។ (សូមមើលការភ្ជាប់ជូននៅចុងឯកសារជំនួយមេរៀន)។ |
| Cash-in-hand | ប្រាក់ដែលនិយោជក និងនិយោជិត មិនបានប្រកាសទៅរដ្ឋាភិបាល។ និយោជិត ដែលទទួលបានបៀវត្សរ៍របៀបនេះ មិនត្រូវបានគេរាប់បញ្ចូលទៅក្នុងការធានារ៉ាប់រងលើគ្រោះថ្នាក់ និងសុវត្ថិភាពការងារនោះទេ។ ការធ្វើការដែលទទួលបានលុយសុទ្ធបែបនេះ គឺជារឿងខុសច្បាប់។ |
| Casual | ការងារមិនទៀងទាត់ គឺគិតតាមម៉ោង និងមិនមានសុវត្ថិភាពការងារទេ។ ការងារបែបនេះច្រើនតែមិនបានទទួលបៀវត្សរ៍សម្រាប់ការឈប់សម្រាកវិស្សមកាល និងពេលមានជំងឺឡើយ ហើយបុគ្គលិកអាចត្រូវនិយោជកបណ្តេញចេញពីការងារបានគ្រប់ពេលវេលា។ |
| Contract | លក្ខខណ្ឌ និងរយៈពេលការងារ ដែលបានចុះហត្ថលេខា និងយល់ព្រម |

ABC Radio Australia
radioaustralia.net.au
AMES
www.ames.net.au
© RadioAustralia/AMES 2008

| | |
|---|---|
| | ដោយនិយោជក និងនិយោជិត។ កិច្ចសន្យា អាចមានរយៈពេលពី ៣ខែ ទៅ ៣ឆ្នាំ ឬលើសពីនេះ។ |
| Full-time | ជាធម្មតានៅប្រទេសអូស្ត្រាលី គឺមានន័យថាធ្វើការ៣៨ម៉ោងក្នុងមួយសប្តាហ៍ (៥ថ្ងៃក្នុងសប្តាហ៍)។ |
| Induction | រៀនសូត្រនូវដំណើរការ និងបែបបទនៅកន្លែងធ្វើការថ្មី។ នៅពេលលោកអ្នកចាប់ផ្តើមការងារថ្មី លោកអ្នកត្រូវឆ្លងកាត់ដំណាក់កាលណែនាំឲ្យស្គាល់កន្លែងការងារសិន ដើម្បីឲ្យលោកអ្នកបានដឹងពីកន្លែងដាក់សម្ភារៈ របៀបធ្វើការ និងការចុះឈ្មោះដើម្បីទទួលបានប្រាក់កម្រៃ។ល។ |
| Leave | នៅក្នុងបរិបទកន្លែងធ្វើការងារ ការឈប់សម្រាកមានន័យថា ថ្ងៃមិនបានធ្វើការ តែទទួលបានប្រាក់កម្រៃ ដូចជាការឈប់ដោយសារការឈឺ ឬការឈប់សម្រាកប្រចាំឆ្នាំជាដើម។ល។ |
| Probationary period<br>“trial run” | ជាទូទៅ ដំណាក់កាលសាកល្បង មានរយៈពេលរាប់អាទិត្យ ឬរាប់ខែ ដើម្បីអាចឲ្យនិយោជក សម្រេចចិត្តថា គួរយកលោកអ្នកធ្វើជាបុគ្គលិកពេញសិទ្ធិឬជាប់លាប់ដែរឬទេ។ ក្នុងដំណាក់កាលនេះ លោកអ្នកនឹងទទួលបានប្រាក់កម្រៃ។ |
| Tax<br>Tax-free threshold | ពន្ធ គឺជាបរិមាណទឹកប្រាក់ដែលកាត់ចេញពីប្រាក់បៀវត្សរ៍ សម្រាប់បង់ជូនទៅរដ្ឋាភិបាល។ សិស្សបរទេសដែលស្នាក់នៅប្រទេសអូស្ត្រាលីលើសពី៦ខែ មិនចាំបាច់បង់ពន្ធលើទឹកប្រាក់ចំនួន $៦០០០ ដែលខ្លួនរកបានជាលើកដំបូងនោះទេ។ បរិមាណទឹកប្រាក់នេះហៅថា កម្រិតបៀវត្សរ៍មិនជាប់ពន្ធ។ |
| Union | និយោជិតនៅប្រទេសអូស្ត្រាលីភាគច្រើន គឺជាសមាជិករបស់សហជីពពាណិជ្ជកម្ម។ អ្នករៀបចំសហជីព អាចជួយនិយោជិតបាន ប្រសិនបើនិយោជិត ទទួលរងនូវការប្រព្រឹត្តិបំពាននៅកន្លែងធ្វើការ។ |

**<u>ភាសា</u>**

ទាំងនេះគឺជាឃ្លាដែលមានន័យមិនធម្មតា និងសំនួនវោហារដែលដកស្រង់ចេញពីការសន្ទនា។

| | |
|---|---|
| “I’ll have a look at your resume.” | ខ្ញុំនឹងអានប្រវត្តិរូបសង្ខេបអំពីការងារ និងការសិក្សារបស់អ្នក។ |


© RadioAustralia/AMES 2008

| | |
|---|---|
| "I'm pleased to say…" | ខ្ញុំមានដំណឹងល្អប្រាប់អ្នក... |
| That's fantastic! | ពិតជាដំណឹងដ៏ល្អមែន។ |

**EXERCISES**
**លំហាត់**

**១. វាក្យសព្ទសំខាន់ៗ**

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក ៖

| | | |
|---|---|---|
| local (locally) | official (officially) | (to) notice |
| application | successful | position |

**២. ការហាត់រៀនភាសា៖ លំហាត់គំរូ -ការធ្វើតេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស**
ដើម្បីអាចចូលរៀនក្នុងវគ្គសិក្សាណាមួយនោះ លោកអ្នកត្រូវធ្វើតេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេសជាមុនសិន។ សូមចាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅ សរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។

Choose the word that best completes each sentence.
ចូរជ្រើសពាក្យដែលស័ក្តិសមបំផុតសម្រាប់ដាក់ទៅក្នុងចន្លោះពាក្យនៃឃ្លាក្នុងប្រអប់ខាងក្រោម។
សូមគូសខ្វែងក្នុងប្រអប់មួយនៃលេខនីមួយៗ។ ឧទាហរណ៍ ☒

1. Yes, I've worked in a restaurant ______________.
   ☐ ago ☐ since ☐ past ☐ before

2. Will there _______________ on the job training?
   ☐ do ☐ be ☐ work ☐ provide

3. I have six ____________ experience.
   ☐ years' ☐ year ☐ times ☐ time

4. You'll need to read ______________ the induction kit.
   ☐ through ☐ on ☐ around ☐ for


© RadioAustralia/AMES 2008

5. I look _______________ to working with you.

☐ forward ☐ toward ☐ ahead ☐ future

## ៣. ឧបសគ្គក្នុងការប្រើប្រាស់ភាសា

សូរសំឡេង / ʊ / and / u:/ ៖ សូមហាត់រៀនពាក្យដូចខាងក្រោមនេះដែលត្រូវពត់អណ្តាតហើយបញ្ចេញសំឡេងឲ្យបានឮៗ ៖

**"The good cook took food to Luke."**

## ៤. អាសយដ្ឋានអ៊ីនធើរណិតមានប្រយោជន៍

| | |
|---|---|
| **ព័ត៌មាន ៖** ការប្រៀបធៀបតួលេខប្រាក់បៀវត្សរ៍នាពេលបច្ចុប្បន្ន | http://content.mycareer.com.au/salary-centre/?ads=0&s_cid=215859 |
| អំពីការងារសម្រាប់សិស្សនិស្សិត | http://www.services.unimelb.edu.au/careers/student |
| អំពីការបង់ពន្ធ | http://www.services.unimelb.edu.au/careers/student/wages/tax.html |
| ការដាក់ពាក្យសុំលេខពន្ធ | http://www.ato.gov.au/ |

ចម្លើយលំហាត់ទី 2: 1) before 2) be 3) years' 4) through 5) forward

ABC Radio Australia


© RadioAustralia/AMES 2008